## ថ្ងៃនេះហើយជាឱកាសស្រួល

វេលានេះឯងជាកំណត់ពេល ឲ្យអ្នកបានសង្គ្រោះ ដ្បិតព្រះទ្រង់បង្គាប់មនុស្សទាំងឡាយនៅគ្រប់អន្លើថា ឲ្យឈឺចិត្តខ្លាសបាបឥឡូវនេះចុះ ដ្បិតទ្រង់បានដាក់កំណត់ថ្ងៃនឹងជំនុំជំរះលោកីយដោយយុត្តិធម៌ ហេតុនោះទ្រង់មានបន្ទូលថា មើល ឥឡូវនេះជាវេលាសម្រេច ឥឡូវនេះជាថ្ងៃសង្គ្រោះ ។

សូមពិចារណាមែនទែន តើអ្នកចង់បានសង្គ្រោះឬទេ សេចក្ដីនេះជាធំបំផុត ពីព្រោះបើព្រលឹងអ្នកធ្លាក់ទៅនរកបង់ នោះអ្នកមិនដែលបានសុខទៀតទេ គឺនឹងត្រូវរងទុក្ខវេទនាទាំងយប់ទាំងថ្ងៃ ជារៀងរាបដរាបតទៅវិញ ហេតុនោះសូមយកចិត្តទុកដាក់ជឿដល់ព្រះយេស៊ូវនៅវេលានេះចុះ ។ អ្នកតែង ហ្វរដ៍ ពរទ័រ

# របៀបព្រះជួយសង្គ្រោះដោយងាយ



ពាក្យសំនួរសួរនេះហើយជាសំខាន់បំផុត ដ្បិតសុខទុក្ខអ្នកលុះអស់កល្បរៀងទៅ នោះស្រេចនូវការនោះឯង គឺថា តើអ្នកបានសង្គ្រោះរួចហើយឬនៅ ? ។

សេចក្តីនេះមិនសួរថា តើអ្នកកាន់សាសនាណានោះទេ គឺសួរដូច្នេះវិញថា តើអ្នកបានសង្គ្រោះរួចពីបាបហើយឬនៅ ពីព្រោះគ្មានអ្នកណាអាចនឹងសោយសម្បត្តិស្ថានសួគ៌បានទេ លើកតែបានសង្គ្រោះរួចទើបបាន ព្រះយេស៊ូវមានបន្ទូលថា ត្រូវតែកើតជាថ្មីឲ្យបានត្រឡប់ជាកូនរបស់ព្រះ ដូច្នេះទ្រង់បានបើកសំដែងឲ្យស្គាល់របៀបតែ១របស់ផងព្រះ ដើម្បីឲ្យបានសង្គ្រោះរួចដោយងាយ ។

## ត្រូវតែយល់ព្រមថា ខ្លួនជាអ្នកបាប

គ្មានអ្នកណាមួយសុចរិត តែមួយក៏គ្មានផង គ្មានសេចក្តីខុសពីគ្នាទេ ដ្បិតគ្រប់គ្នាបានធ្វើបាប ហើយខ្វះធ្វើមិនដល់សិរីល្អព្រះទេ បើមិនយល់ឃើញថា ខ្លួនជាអ្នកបាបនោះមិនអាចនឹងបានសង្គ្រោះទេ ឈ្នួលអំពើបាប គឺជាសេចក្តីស្លាប់ អំពើបាបនោះបង្កើតសេចក្តីស្លាប់ សេចក្តីនោះបំភាសឲ្យប្រាសឃ្លាតដាច់ពីព្រះចេញ ធ្លាក់នរកអស់កល្បជានិច្ចទៅ នោះហើយជាសណ្ឋានវេទនាណាស់ណាគួរសោកស្តាយជាខ្លាំង ។

## ព្រះទ្រង់មេត្តាប្រោស

ព្រះទ្រង់ស្រឡាញ់អ្នកដល់ម្ល៉េះ បានជាប្រទានព្រះរាជបុត្រាទ្រង់តែ១ គឺជាអង្គព្រះយេស៊ូវគ្រីស្ទ ឲ្យមកទទួលសុគតជំនួសអស់ទាំងមនុស្សមានបាប ទ្រង់មិនបានស្គាល់បាបសោះ តែទ្រង់បានត្រឡប់ជាបាបជំនួសយើងរាល់គ្នា ដើម្បីឲ្យយើងរាល់គ្នា បានត្រឡប់ជាសុចរិតរបស់ព្រះវិញ ព្រះទ្រង់បានផ្ទុកអស់ទាំងអំពើបាបយើងរាល់គ្នា លើរូបអង្គទ្រង់នៅលើឈើឆ្កាង ដើម្បីឲ្យយើងរាល់គ្នាបានរស់ខាងឯសេចក្តីសុចរិតវិញ គឺដោយស្នាមដំទ្រង់ ដែលយើងរាល់គ្នាបានជា ទ្រង់មានបន្ទូលថា បាបរបស់អ្នកបានផ្ទុកលើអង្គព្រះយេស៊ូវរួចស្រេចអស់ហើយ ការនោះប្រាកដមែន ដ្បិតព្រះទ្រង់មិនអាចនឹងកុហកទេ ។

## ត្រូវជឿដល់ព្រះយេស៊ូវគ្រីស្ទ ឲ្យបានសង្គ្រោះ

តើត្រូវធ្វើដូចម្តេចឲ្យបានសង្គ្រោះ ? ត្រូវតែជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ នោះនឹងបានសង្គ្រោះរួច គឺឲ្យជឿជាក់អស់ពីចិត្តថា ព្រះយេស៊ូវបានទទួលរងទុក្ខទោសដើម្បីនឹងធ្វើឲ្យធួននឹងបាបអ្នក រួចទ្រង់មានព្រះជន្មរស់ឡើង ដើម្បីឲ្យអ្នកបានរាប់ជាសុចរិតវិញ ។

## ត្រូវតែអំពាវដល់ព្រះនាមព្រះអម្ចាស់ ឲ្យបានសង្គ្រោះ

ពាក្យអធិស្ឋានមុនបង្អស់ ដែលត្រូវតែទូលថ្វាយព្រះគឺថា «ឱព្រះអង្គអើយ សូមមេត្តាអត់ទោសឲ្យទូលបង្គំជាអ្នកមានបាបផង ទូលបង្គំស្តាយណាស់ ដែលខ្លួនបានប្រព្រឹត្តដូច្នោះ បានជាសូមទ្រង់មេត្តាប្រោសជួយសង្គ្រោះទូលបង្គំឲ្យរួចដោយនូវព្រះគុណព្រះយេស៊ូវ» រួចឲ្យអ្នកជឿជាក់ដោយអាងតាមព្រះបន្ទូលចុះ ។

## សម្រាប់គ្រប់គ្នា អ្នកណាក៏ដោយ

ដ្បិតអ្នកណាអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ ពាក្យដែលថា អ្នកណា នោះគឺស្រាយថា គ្រប់គ្នា អ្នកឯណាក៏ដោយ ទោះមានបាបក្រាស់ឬស្តើងក្តី ព្រមទាំងខ្លួនអ្នកដែលកំពុងអានមើលសេចក្តីនេះផង ឲ្យគ្រាន់តែអាងដល់ព្រះបន្ទូលដោយស្មោះត្រង់ នោះទើបបានរួចភ្លាម ដូច្នេះចូរទទួលយកសេចក្តីសង្គ្រោះពីព្រះមក ដោយទុកចិត្តជឿច្បាស់ប្រាកដតាមព្រះបន្ទូលពិតដែលថា «ឲ្យជឿ នោះបានសង្គ្រោះហើយ» ឥតកសាងធ្វើបុណ្យកុសលឯណាសោះឡើយ ។